# ប្រវត្តិសាស្ត្រព្រះពុទ្ធសាសនា

អារ្យធម៌ដែនជម្ពូទ្វីប

តាំងពី ២៦០០ឆ្នាំ មុនគ្រឹះសករាជ ឬ១៥០០- (២០០០ដល់៩០០ឆ្នាំមុនពុទ្ធសករាជ) សិន្ធុទន្លេសណ្ដអារ្យធម៌នាយុគ ( Indus civilization ឬហៅថា Harappan civilization )មានការគាស់ឃើញបូរាណស្ថានសំខាន់មួយនៅ Mohenjo Daro ភាគឦសាននៃក្រុងការាចីប្រទេសបាកីស្ថាននិង Harappa ចម្ងាយពីកន្លែងដើមប្រមាណ ៥០ម៉ែល៍ ជាអារ្យធម៌មានចំណាស់ជាងគេក្នុងភូមិភាគអាស៊ីខាងត្បូង នៃយុគស្ពាន់សំរឹទ្ធ )Bronze Age) ជាកំឡុងពេលជាមួយគ្នានៃអារ្យធម៌អេហ្ស៊ីបបូរាណ អារ្យធម៌សោប៉ូតេនៀ និងអារ្យធម៌មិនូអ័ននៃកោះក្រេត )Crete) ។

អារ្យធម៌នាសម័យនេះមានការរីកចម្រើនខ្លាំងណាស់ ទីក្រុងដែលមានការរចនាប្លង់ដ៏ឆ្នើម ព្រមទាំងប្រព័ន្ធធារាសាស្ត្រ ចេះសរសេរអក្សរ មានមាត្រា ថ្លឹង រង្វាស់រង្វាល់ មានការគោរព បូជាព្រះអាទិទេពដែលមានលក្ខណៈប្រហែលគ្នា និងការគោរពព្រះសិវៈនាសម័យក្រោយមក ។ អារ្យធម៌នេះបានពង្រីកខ្លួនយ៉ាងទូលំទូលាយ ភាគខាងលិចដល់ជាយដែនអ៊ីរ៉ង់ (Iran) ខាងជើងទៅដល់អាហ្វហ្គានិស្ថាន )Afghanistan) ខាងកើតមកដល់ទីក្រុងដេលី )Delhi) បច្ចុប្បន្ន ។

តាំងពី ១៥០០ ដល់ ១២០០ មុនគឆ្នាំ មុន ព៦០០-៩០០) .ស..ស(. កុលសម្ពន្ធអារិយ៉ែន ) បានដណ្ដើមយកតំបន់ខ្ពង់រាបរបស់អ៊ីរ៉ង់ (អារិយកៈ)Iran) ឬប៉ើរសៀ )Persia) ហើយ ចូលមករុករានគ្រប់គ្រងរហូតដល់ឆ្នេរសមុទ្រគង្គារ ព្រមទាំងនាំសាសនាព្រាហ្មណ៍ ភាសាសំស្រ្កឹត និងរបបវណ្ណៈមកជាមួយផងអារ្យធម៌ចាប់ផ្ដើមឈានមកដល់យុគលោហៈ ។

## សម័យពុទ្ធកាល

ជម្ពូទ្វីបនិងព្រះពុទ្ធសាសនា

## Ø អាណាខែត្រក្នុងជម្ពូទ្វីប

៦២៣ ឆ្នាំមុនគសោឡស) ខែត្រដែន១៦ ជម្ពូទ្វីបចែកចេញជា .ស. មហាជនបទ ( ប្ញ៉ាទៅដល់ទិសពាយ័ព្យ គឺ អង្គ: មគធ: កាសី កោសល វជ្ជិទិសរាប់ពី មល្ល: ចេតី វង្ស: កុរុ បញ្ចាល: មច្ឆ: សុរសេន: អស្សក: អវន្តី គន្ធារ: កម្ពោជ: ជូនកា)លកម្ពោជ: ប្រើគួបផ្សំជាមួយយោនៈទៅជា យោនកម្ពោជៈ១៦ទាំង ( ដែននេះ ដែនខ្លះសាបសូន្យអន់ថយអំណាច ដែនខ្លះរុងរឿងមានអំណាចឡើង ជាពិសេស គឺដែនមគធ: ។

## Ø ប្រសូតិ ត្រាស់ដឹង ផ្សព្វផ្សាយសាសនា

៨០ ឆ្នាំមម ៦២៣).ស.ព..គឬ បរទេស ពោល( មុនគ្រឹះសករាជ=.ស.គ.ម) .ស. ថា ៥៦៣ ម(.ស.គ. ព្រះសិទ្ធត្ថរាជកុមារ រាជឱរសរបស់ព្រះបាទសិទ្ធោទន: និង ព្រះនាងសិរីមហាមាយានៃសក្យត្រកូលបានប្រសូត នាព្រៃលុម្ពិនីចន្លោះនគរ ទាំងពី គឺកបិលព័ស្តុ និងទេវទហ: ក្រោយពី ប្រសូត បាន៧ថ្ងៃ ព្រះពុទ្ធមាតា ទ្រង់សោយវិលាល័យ ។ ៥១ ឆ្នាំ មម ៥៩៤) .ស.ព..គព្រះរាជកុមារ ចេញ (.ស. ទ្រង់ព្រះផ្នួស ក្នុងព្រះជន្មាយុ (មហាភិនិស្រ្កម) ២៩ព្រះវស្សានាស្ទឹងអនោមានទី ។ ៤៥ ឆ្នាំមម ៥៨៨) .ស.ព..គ(.ស. នាថ្ងៃពេញបូណ៌មីខែវិសាខ ព្រះសិទ្ធត្ថរាជ កុមារ ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណ ជាព្រះពុទ្ធ ជាម្ចាស់ នៅក្រោមដើមពោធិក្បែរឆ្នេស្ទឹងនេរញ្ជរា ស្រុកឧរុវេលសេនានិគម (បច្ចុប្បន្នហៅថា ពុទ្ធគយា។វស្សា ព្រះ៣៥ ដែនមគធ ក្នុងព្រះជន្មាយុ (

២ ខែក្រោយមក នៅថ្ងៃពេញបូណ៌មីខែអាសាធ ព្រះពុទ្ធអង្គទ្រង់សម្តែង បឋមទេសនា ធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គី នាព្រៃឥសិបត្តនមិគ្គទាយវ៉ន ក្រុងពារាណសី ។ នៅក្នុងព្រៃនោះក្រោយមកមិនយូរក្រៅពី មាន យសកុលបុត្ត ម្នាក់ និងសំឡាញ់៥៤នាក់ទៀតចេញបួសហើយ នៅមានព្រះអរហន្តកើត ឡើងក្នុងលោកទៀតផង ទើបព្រះអង្គទ្រង់បញ្ជូនចេញទៅផ្សព្វផ្សាយ ព្រះពុទ្ធ សាសនាដោយព្រះតម្រាស់ថា “ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ” ប្រែថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចារិកទៅកាន់ទីទាំងពួងដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ និងដើម្បី អនុគ្រោះដល់សត្វលោកចុះ”

## Ø ប្រតិស្ថានព្រះពុទ្ធសាសនានាមគធនគរ

បន្ទាប់ពីបានត្រាស់ដឹងបាន៩ខែ ក្រោយពីប្រោសបញ្ចវគ្គីនាព្រៃឥសិបត្តនមិគ្គទាយវ័ន ទីក្រុងពារាណសីរួចហើយ ព្រះអង្គទ្រង់ធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ ដើម្បីប្រោសជដិលបីនាក់បងប្អូនរួមបរិវារ ១000 នាក់ ឯគយាសីសៈប្រទេស ហើយស្តេចនិមន្តទៅប្រោសព្រះបាទពិម្ពិសារ ជាមួយរាជបរិពារ ក្រោយមក ព្រះបាទពិម្ពិសារទ្រង់បានប្រគេនវត្តវេឡុវ័ន ជាអារាមមុនដំបូងបំផុតក្នុងព្រះពុទ្ធសាសនា ។ ទ្រង់បំពេញពុទ្ធកិច្ចដើម្បីប្រតិស្ថានព្រះពុទ្ធសាសនា ក្នុងដែនមគធៈ ទ្រង់ទទួលបាននូវអគ្គសាវកពីរអង្គគឺ ព្រះសារីបុត្រនិង ព្រះមហាមោគ្គលាន (អតីតជាបរិពាជកឈ្មោះឧបតិសៈនិងកោលិតៈ ( នាក់ទៀត ។២៥០ ព្រមទាំងបរិវារ បន្ទាប់ពីព្រះសារីបុត្តបាន បន្លុះ ព្រះអរហត្តផល លុះដល់ថ្ងៃពេញបូណ៌មីខែមាឃ ព្រះពុទ្ធអង្គ ទ្រង់ជំនុំ ព្រះអរហន្ត ១២៥០ អង្គ សម្តែងឱវាទបាដិមោក្ខ ហៅថា ចតុរង្គសន្និបាត ។ លុះដល់ឆ្នាំទី ៣ នៃពុទ្ធកិច្ច អនាថបណ្ឌិកសេដ្ឋីបានថ្វាយខ្លួនជាឧបាសក មានបសាទសទ្ធាក្នុងព្រះពុទ្ធសាសនា បានសាងវត្តជេតពនប្រគេន ព្រះពុទ្ធជាម្ចាស់ នៅក្រុងសាវត្ថីដែនកោសល ជាអារាមដែលព្រះពុទ្ធជាម្ចាស់ទ្រង់ប្រថាប់គង់នៅច្រើនជាងគេបង្អស់ ប្រមាណ ១៩ព្រះវស្សា ។ បន្ទាប់មក គឺ វត្តបុព្វារាមក្រុងសាវត្ថីដែល សាងថ្វាយដោយនាងវិសាខាមហាឧបាសិកា ទ្រង់ចាំវស្សា៦ ព្រះវស្សា ។

## Ø ពុទ្ធកិច្ច ៤៥ ព្រះវស្សា

អស់កាល៤៥ព្រះវស្សា ព្រះពុទ្ធអង្គស្តេចនិមន្តទៅចាំព្រះវស្សា ក្នុងទីផ្សេងៗ ព្រមទាំងមានហេតុការណ៍សំខាន់ ៗ មួយចំនួន ដែលកត់សំគាល់ ដូចត ទៅនេះ៖

- វស្សាទី ១ ព្រៃឥសិបត្តនមិគ្គទាយវ័ន ក្បែរក្រុងពារាណសី ប្រោសបញ្ចវគ្គី ។
- វស្សាទី ២វត្តវេឡុវ័ន ៤-៣- ក្រុងរាជគ្រឹះ រយៈពេលប្រកាសព្រះសាស)នា ចាប់ផ្តើមតាំងពីប្រោសព្រះបាទពិម្ពិសារ បានអគ្គសាវក ។ល។ ស្តេចនិមន្តទៅកាន់នគរកបិលព័ស្តុលើកដំបូង ។ល។ អនាថបិណ្ឌិកសេដ្ឋីថ្វាយខ្លួនជា

ឧបាសកសាងវត្តជេតពន ។ តែបើគិតតាម ព្រះវិន័យបិដក វស្សាទី ៣ប្រហែលជាទ្រង់ចាំវស្សានៅវត្តជេតពនក្រុងសាវត្ថី ។

- វស្សាទី ៥ កូដាគារ ក្នុងព្រៃមហាវនក្រុងវេសាលី (ប្រោសព្រះពុទ្ធបិតាដែលចូលកាន់និព្វាននៅក្រុងកបិលព័ស្តុ
ប្រោសព្រះញាតិដែលវិវាទគ្នារឿងស្ទឹងរោហិណី
និងព្រះនាងមហាបជាបតិគោតមី
ចេញសាងផ្នួសបួសជាភិក្ខុនីមុនគេបង្អស់។ (
- វស្សាទី ៦ មកុលបពិត យមកប្បដិហារិយ៍នាទ្រង់សម្ដែងហើយក្រោយមក) ក្រុងសាវត្ថី។ (
- វស្សាទី ៧ ស្ថានតាវតិង្ស សម្ដែងព្រះអភិធម្មទេសនាប្រោសពុទ្ធមាតា ។
- វស្សាទី ៨ ភេសកលាវ័ន ក្បែរក្រុងសុង្សុមារគិរី ដែនភគ្គៈ ទ្រង់បានជួបនឹងនកុលបិតានិងនកុលមាតា ។
- វស្សាទី ៩ ឃោសិតារាម ក្រុងកោសម្ពី ។
- វស្សាទី ១០ ព្រៃបាលិលយកៈ ក្បែរក្រុងកោសម្ពី ពេលភិក្ខុកើ)តវិវាទគ្នា។ (
- វស្សាទី ១១ ឯកនាលា ព្រាហ្មណគាម ។
- វស្សាទី ១២ ស្រុកវេរញ្ជា ។
- វស្សាទី ១៣ ចាលិយបពិត ។
- វស្សាទី ១៤ វត្តជេតពន ព្រះរាហុលទទួលឧបសម្បទា ។
- វស្សាទី ១៥ និគ្រោធារាម នគរកបិលព័ស្តុ ។
- វស្សាទី ១៦ ទីក្រុងអាឡវី ទ្រង់ធ្វើទុក្ករកម្មចំពោះអាឡវកយ័ក្ស ។
- វស្សាទី ១៧ វត្តវេឡុវ័ន ក្រុងរាជគ្រឹះ ។
- វស្សាទី ១៨ចាលិយបពិត ។ ១៩-
- វស្សាទី ២០ វត្តវេឡុវ័ន ក្រុងរាជគ្រឹះ ទ្រង់ប្រោសអង្គុលីមាល និងទ្រង់តែងតាំងព្រះអានន្ទ ធ្វើជាពុទ្ធុប្បដ្ឋាក ។
- វស្សាទី ២១ ៤៥- ទ្រង់គង់ផ្លាស់ប្ដូរគ្នារវាង វត្តជេតពន និងវត្តបុព្វារាម ទីក្រុងសាវត្ថី រួមទាំងមុនទាំងក្រោយអត្ថកថា ពោលថា ព្រះពុទ្ធជាម្ចាស់ទ្រង់គង់នៅវត្តជេតវនារាម១៩ ព្រះវស្សា និងវត្តបុព្វារាម ៦ ព្រះវស្សា ។
- វស្សាទី ៤៥ ទ្រង់គង់នៅវេឡុវគាម ក្បែរក្រុងវេសាលី ។

## Ø ពុទ្ធកិច្ចប្រចាំថ្ងៃ

ក្រៅអំពីការទ្រង់ចាំវស្សាទាំង ៤៥ឆ្នាំ តាមវត្តនានាហើយ ព្រះអត្ថកថាចារ្យនៅបានរួបរួមពុទ្ធកិច្ចប្រចាំថ្ងៃរបស់ព្រះអង្គថែមទៀត ហៅថា ពុទ្ធកិច្ចប្រចាំថ្ងៃមាន ៥ គឺ

១.បុព្វណ្ហេ បិណ្ឌបាតញ្ច ពេលព្រឹកទ្រង់បិណ្ឌបាត

២.សាយណ្ហេ ធម្មទេសនំ ពេលរសៀលទ្រង់សម្តែងព្រះធម៌ទេសនា

៣.បទោសេ ភិក្ខុឱវាទំ ពេលព្រលប់ទ្រង់ប្រទានឱវាទដល់ភិក្ខុ

៤.អឌ្ឍរត្តេ ទេវបញ្ហានំ កណ្តាលអាធ្រាតទ្រង់ដោះស្រាយប្រស្នាពពួកទេវតា

៥.បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកានំ ទៀបភ្លឺទ្រង់ប្រមើលមើលនូវវេនេយ្យសត្វ ។

ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោ ព្រះពុទ្ធមុនីដ៏ប្រសើរ ទ្រង់ញ៉ាំងពុទ្ធកិច្ចទាំងប្រាំនេះឲ្យសម្រេចហ្មត់ចត់ដោយបរិបូណ៌ពិត ។

## Ø គំរូសង្គាយនា និងបច្ឆិមពុទ្ធវចនៈ

ឆ្នាំ ៥២៧ មមហាវីរៈ (តាមបស្ចឹមប្រទេស) .ស.គ. (និគ្រន្ថនាដបុត្រ ( ជិនៈ អស់ព្រះជន្ម/សាស្តាជេន សាវកក៏កើតវិវាទទោះទែងគ្នាអំពីពាក្យប្រៀនប្រដៅរបស់សាស្តាខ្លួន ជាហេតុនាំឲ្យ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រារព្ធ ណែនាំឲ្យមានការសង្គាយនាព្រះធម៌វិន័យឡើង ហើយមានគ្រាមួយព្រះសារីបុត្របានសម្តែងសង្គីតិសូត្រទុកជាគំរូនៃការ ធ្វើសង្គាយនា ។ ១ឆ្នាំ មម ៥៤៣=).ស.ព..គ.ស. (.ស.គ.ម៥៨៣ខ្លះថា នាថ្ងៃពេញបូណ៌ខែវិសាខ ក្រោយពីបំពេញពុទ្ធកិច្ច ៤៥ ព្រះវស្សារួច ព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះជន្មាយុ ៨០ព្រះវស្សា ព្រះអង្គទ្រង់រំលត់ខន្ធចូលកាន់បរិនិព្វាន ក្រោមដើមរាំងទាំងគូ ក្រុងកុសិណារា ។ បច្ឆិមពុទ្ធវចនៈ "...ខយវយធម្មា សង្ខារា អប្បមាទេន សម្បទេថ សង្ខារធម៌ទាំងឡាយមានកិរិយាអស់ទៅនិងសូន្យទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឲ្យដល់ព្រមដោយសេចក្តីមិនប្រមាទចុះ" ។

សូមអស់លោកអ្នកអនុមោទនា!            (ចប់)